ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ:...០១២......សហវ.....

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦

# សារាចរ

## ស្តីពី

## ការណែនាំលើការអនុវត្តន៍ថវិកាឆ្នាំ ២០០៧

### I. សេចក្តីផ្តើម

១. ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ។ ដោយផ្អែកលើច្បាប់នេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានចេញប្រកាសលេខ ១៤០១ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្ត ចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ ។ ដើម្បីអនុវត្តច្បាប់នេះ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យ លេខ ១៧០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណូលថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ និង អនុក្រឹត្យលេខ ១៧១ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋ តាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧ ។ ដោយផ្អែកលើមូលដ្ឋាននៃច្បាប់ និង អនុក្រឹត្យនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានចេញ ប្រកាសលេខ ១៤០២ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តប្លង់គណនេយ្យទូទៅ នៃគណនេយ្យរដ្ឋ ប្រកាសលេខ ១៤០៣ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្ត ប្លង់គណនេយ្យទូទៅនៃគណនេយ្យថវិកាខេត្ត-ក្រុង ប្រកាសលេខ ១៤០៤ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តប្លង់គណនេយ្យទូទៅនៃគណនេយ្យថវិកាស្រុក-ខ័ណ្ឌ ប្រកាសលេខ ១៤០៥ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការរៀបចំ និង កិច្ចដំណើរការគណនីនៃរដ្ឋទេយ្យចំណូល ប្រកាសលេខ ១៤១៥ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការប្រគល់សិទ្ធិជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលនៅអមផ្ទាល់តាមក្រសួងស្ថាប័ននៅរដ្ឋបាលកណ្តាល ក្នុងការពិនិត្យសំរេចចុះទិដ្ឋាការលើលិខិតធានាចំណាយ និង លើអាណត្តិបើកប្រាក់ ប្រកាសលេខ ១៤១៦ សហវ.ប្រក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការប្រគល់ ភារកិច្ចប្រមូលចំណូលថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ប្រកាសលេខ ១៤១៧ សហវ.ប្រក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពី ការបែងចែកចំណាយឥណទានថវិកាផ្ទេក្នុងជំពូកតាម គណនី និង អនុគណនី

សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ សារាចរណែនាំលេខ ០១៣ សហវ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការគ្រប់គ្រងវដ្តទេយ្យចំណូល សារាចរណែនាំលេខ ០១៤ សហវ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការចំណាយតាមនីតិវិធីវដ្តទេយ្យបុរេប្រទាន និង សារាចរណែនាំលេខ ០១៥ សហវ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការកាត់បន្ថយនីតិវិធីនៃការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយសាធារណៈ ។ ដើម្បីឱ្យការអនុវត្តន៍ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ មានដំណើរការប្រកបដោយលទ្ធផលល្អ និង មានប្រសិទ្ធភាពខ្ពស់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមធ្វើការណែនាំលើការអនុវត្តន៍ថវិកាជាតិ ឆ្នាំ ២០០៧ ដែលមានតាមលំដាប់លំដោយដូចតទៅ ។

២- ថវិកាឆ្នាំ ២០០៧ ត្រូវបានរៀបចំឡើងដោយផ្អែកលើ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ជាពិសេសដើម្បីបំរើអោយការបន្តអនុវត្ត **យុទ្ធសាស្ត្រចតុកោណ** ដើម្បី ***កំណើន ការងារ សមធម៌*** និង ***ប្រសិទ្ធភាព*** ។ រាជរដ្ឋាភិបាលនឹងបន្តជំរុញការអនុវត្តន៍យុទ្ធសាស្ត្រទាំង ៤ គឺ (១) ការជំរុញការអភិវឌ្ឍវិស័យកសិកម្ម និង កសិឧស្សាហកម្ម (២) ការជំរុញការអភិវឌ្ឍវិស័យឯកជន និង បង្កើតការងារ (៣) ការបន្តស្តារ និង កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាពិសេសប្រព័ន្ធធារាសាស្ត្រ និង (៤) ការបន្តជំរុញការកសាងសមត្ថភាពស្ថាប័ន និង ការអភិវឌ្ឍន៍ធនធានមនុស្ស ព្រមទាំងបន្តជំរុញអោយកាន់តែខ្លាំងក្លាថែមទៀតលើការដ្ឋានទាំង ៤ នៃ អភិបាលកិច្ចល្អគឺ (១) ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ (២) កំណែទំរង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ (៣) កំណែទំរង់រដ្ឋបាលសាធារណៈ និង (៤) កំណែទំរង់កងកំលាំងប្រដាប់អាវុធ ។ ទន្ទឹមនឹងនេះ ដើម្បីបន្តបង្កើនភាពស័ក្តិសិទ្ធិ និង ប្រសិទ្ធភាពនៃប្រតិបត្តិការរបស់រាជរដ្ឋាភិបាល ជាពិសេស បង្កើនគុណភាពនៃការផ្តល់សេវាសាធារណៈ រាជរដ្ឋាភិបាលនឹងបន្តជំរុញ (១) ការអនុវត្តន៍កំណែ ទំរង់រចនាសម្ព័ន្ធ ដើម្បីពង្រឹងបរិស្ថានអំណោយផលសម្រាប់ការអភិវឌ្ឍន៍ផ្នែកឯកជន (២) ការពង្រឹងប្រព័ន្ធធនាគារ និង វិស័យធានារ៉ាប់រង និង ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុទាំងមូល ដើម្បីកៀរគរធនធានហិរញ្ញវត្ថុ សម្រាប់ការធ្វើហិរញ្ញប្បទានគម្រោងរបស់ផ្នែកឯកជន (៣) ការកសាង និង ពង្រឹងការអនុវត្តន៍ច្បាប់ និង បទបញ្ជា ដើម្បីពង្រឹងប្រសិទ្ធភាពការងារ និង អភិបាលកិច្ចល្អ (៤) ការអនុវត្តកំណែទំរង់វិមជ្ឈការ និង វិសហមជ្ឈការ ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលបច្ចេកទេស និង ហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សាឃុំ- សង្កាត់ និង ការអភិវឌ្ឍន៍មូលដ្ឋាន និង (៥) ការបន្តជំរុញការអនុវត្តន៍ ផែនការយុទ្ធសាស្ត្ររយៈពេលមធ្យមនៃវិស័យអប់រំ និង វិស័យសុខាភិបាល និង ការចាប់ផ្តើមអនុវត្តផែនការយុទ្ធសាស្ត្ររយៈពេលមធ្យមសំរាប់វិស័យកសិកម្ម និង ធនធានទឹក ដែលជាវិស័យអាទិភាពនៃគោលនយោបាយចំណាយសាធារណៈរបស់រាជរដ្ឋាភិបាល និង ជាមុខព្រួញចំណាយដ៏សំខាន់ដែលមានឥទ្ធិពលដោយផ្ទាល់ដល់ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។

## II. លំហូរចំណូល និង វិធានការក្នុងការអនុវត្តន៍ថវិកាឆ្នាំ ២០០៧

### ក- ការអនុវត្តន៍ការប្រមូលចំណូលថវិកា

៣. ដើម្បីអោយការអនុវត្តន៍ច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ សំរេចបានជោគជ័យ ជាពិសេស ដើម្បីអោយការអនុវត្តន៍ថវិកាសំរេចបានតាមការគ្រោងទុក ជាក់ស្តែងគឺដើម្បីអោយការប្រមូលចំណូលក្នុងស្រុក សំរេចបានតាមគោលដៅ ៣ ៤០០ ៥៧៣ លានរៀល គឺស្មើនឹង ១០,៩២% នៃផសស រាជរដ្ឋាភិបាលនឹងជំរុញ ការបង្កើនការប្រមូលចំណូលចរន្តអោយបាន ៣ ៣៧០ ៥៧៣ លានរៀល បើធៀបទៅនឹងចំណូលចរន្តនៃច្បាប់ ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៦ គឺនឹងត្រូវកើនឡើង ១៧,៣១% ដែលក្នុងនោះចំណូលសារពើពន្ធនឹងត្រូវ កើន ២០,៩៦% (ចំណូលគយ និង រដ្ឋាករនឹងត្រូវកើន ៩,៩៣% និង ចំណូលពន្ធដារនឹងត្រូវកើន ៥០,៤៨%) និង ចំណូលមិនមែនសារពើពន្ធនឹងត្រូវកើន ២,៧៥% ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានចេញបទបញ្ញាស្តីពីការ គ្រប់គ្រងចំណូលមិនមែនសារពើពន្ធលេខ ០៤ បប ចុះថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ ២០០៦ ដែលរួមមាន វិធានការ ប្រមូលចំណូល វិធានការគ្រប់គ្រងបំណុល និង វិធានការលើកទឹកចិត្ត ពិន័យ និង ទណ្ឌវាទ ក្នុងគោលដៅ ពង្រឹងការប្រមូល និង គ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ។

៤- ថវិកាឆ្នាំ ២០០៧ បានឆ្លុះបញ្ចាំងពីកំនើននៃចំណូលធៀបនឹងចំណូលថវិកាឆ្នាំ ២០០៦ ជាពិសេស ការបង្កើនចំណូលក្នុងស្រុកអោយដល់ ៣ ៤០០ ៥៧៣ លានរៀល គឺស្មើនឹង ១០,៩២% នៃផសស (ចំណូលក្នុង ស្រុកដែលជាថវិការដ្ឋមាន ៣ ២៨២ ១៧៣ លានរៀល គឺស្មើនឹង ១០,៥៤% នៃផសស និង ចំណូលថវិកា ខេត្ត-ក្រុងមាន ១១៨ ៤០០ លានរៀល) ដែលនឹងមានកំនើនស្មើនឹង ១៧,១៧% (ចំណូលថវិការដ្ឋកើន ១៦,៨២% និង ចំណូលថវិកាខេត្ត-ក្រុងកើន ២៧,៨៦%) ធៀបនឹងលទ្ធផលប៉ាន់ស្មានចំណូលថវិកាឆ្នាំ ២០០៦ ។ ការបង្កើន និង ពង្រឹងការកៀរគរចំណូលគឺជាយុទ្ធសាស្ត្រស្នូលនៃគោលនយោបាយថវិកាឆ្នាំ ២០០៧ ជាពិសេស ការផ្តោតជាសំខាន់ទៅលើការពង្រឹងរដ្ឋបាលពន្ធដារ និង រដ្ឋបាលគយ និង រដ្ឋាករ ក្នុងគោលដៅសំរេចឱ្យបាននូវ ចំណូលសារពើពន្ធ ២ ៧៧៨ ៤៥៤ លានរៀល គឺស្មើនឹង ៨,៩២% នៃផសស (ចំណូលសារពើពន្ធជាថវិការដ្ឋមាន ៨,៦១% និង ចំណូលសារពើពន្ធជាថវិកាខេត្ត-ក្រុងមាន ០,៣១%) ដែលមានកំនើនស្មើនឹង ១៦% ធៀបនឹង លទ្ធផលប៉ាន់ស្មានចំណូលថវិកាឆ្នាំ ២០០៦ ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងពង្រឹងការអនុវត្តន៍ឱ្យមាន ប្រសិទ្ធភាពនូវច្បាប់ស្តីពីសារពើពន្ធ ពង្រឹង និង ពង្រីកសមត្ថភាពស្ថាប័ន ពង្រីកមូលដ្ឋានយកពន្ធ ព្រមទាំង ទប់ស្កាត់អំពើរត់ពន្ធគ្រប់បែបយ៉ាង ។ ម្យ៉ាងទៀត ចំណូលមិនមែនសារពើពន្ធនឹងសំរេចអោយបាន ៥៩២ ១១៩ លានរៀល គឺស្មើនឹង ១,៩០% នៃផសស (ចំណូលមិនមែនសារពើពន្ធដែលជាថវិការដ្ឋមាន ៥៧០ ១៧៣ លានរៀល គឺស្មើនឹង ១,៨៣% នៃផសស) បើធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០០៦ គឺមានការកើនឡើង ២,៧៥% (ចំណូលមិនមែនសារពើពន្ធដែលជាថវិការដ្ឋកើនឡើង ២,៤៣% និង ចំណូលមិនមែនសារពើពន្ធដែលជាថវិកា ខេត្ត-ក្រុងកើនឡើង ១១,៩៧%) តែបើធៀបនឹងលទ្ធផលប៉ាន់ស្មានចំណូលថវិកាឆ្នាំ ២០០៦ នឹងកើនឡើង

២៤,៦៦% (ចំណូលមិនមែនសារពើពន្ធដែលជាថវិកាជាតិនឹងកើនឡើង ២៥,២០% និង ចំណូលមិនមែនសារពើពន្ធដែលជាថវិកាខេត្ត- ក្រុងកើនឡើង ១១,៩៧%) ។

៥- ដើម្បីសំរេចបានតាមគោលដៅខាងលើ នាយកដ្ឋានពន្ធដារ និង ទីចាត់ការគយ និង រដ្ឋាករ ត្រូវរៀបចំកម្មវិធីប្រមូលចំណូលសារពើពន្ធប្រចាំត្រីមាសដែលមានការបែងចែកលំអិតទៅតាមខែ ។ បើគិតជាមធ្យមភាគប្រចាំខែ នាយកដ្ឋានពន្ធដារមានភារកិច្ចប្រមូលចំណូលពន្ធផ្ទៃក្នុងឱ្យបានជាមធ្យមចំនួន ៦៥,៨៣ ពាន់លានរៀលក្នុងមួយខែ ។ ចំណែកទីចាត់ការគយ និង រដ្ឋាករមានភារកិច្ចប្រមូលចំណូលពន្ធអាករឱ្យបានជាមធ្យមចំនួនប្រមាណ ១៤៧,៥៨ ពាន់លានរៀលក្នុងមួយខែ ទោះជាការប្រមូលជាក់ស្តែងអាចមានកំរិតខ្ពស់ ឬទាបជាងការគ្រោងទុកបន្តិចបន្តួចទៅតាមស្ថានភាពសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ ។ ទន្ទឹមនឹងនេះ កម្មវិធីប្រមូលចំណូលនេះ ត្រូវមានផែនការសកម្មភាពអនុវត្តលំអិតហើយប្រគល់ឱ្យសាខាទីស្នាក់ការ និង មន្ត្រីម្នាក់ៗដើម្បីទទួលខុសត្រូវដោយផ្ទាល់ទៅតាមភារកិច្ចដែលខ្លួនត្រូវបំពេញរៀងៗ ខ្លួន ។

៦- ដើម្បីសំរេចបាននូវការប្រមូលចំណូលមិនមែនសារពើពន្ធឆ្នាំ ២០០៧ ចំនួន ៥៩២,១១៩ ពាន់លានរៀល ក្រសួង- ស្ថាប័ន និង មន្ទីរជំនាញរបស់ខ្លួននៅតាមខេត្ត-ក្រុងត្រូវរៀបចំកម្មវិធីប្រមូលចំណូលមិនមែនសារពើពន្ធប្រចាំត្រីមាស ដែលមានការបែងចែកលំអិតតាមខែ ដោយផ្អែកលើកិច្ចសន្យានៃការជួលទ្រព្យសម្បត្តិរដ្ឋ កិច្ចសន្យាសម្បទាននានា ចំណូលពីសេវាបង់ថ្លៃសកម្មភាពអាជីវកម្ម និង សង្វាក់នៃការប្រមូលចំណូលកន្លងមក ។ ក្រសួង-ស្ថាប័នត្រូវប្រគល់ការអនុវត្តន៍កម្មវិធីនេះ ទៅឱ្យអង្គភាពក្រោមឱវាទនៅរដ្ឋបាលកណ្តាល និងនៅខេត្ត-ក្រុងអោយទទួលខុសត្រូវដោយផ្ទាល់ចំពោះការប្រមូលចំណូលទាំងនោះ ។ អង្គភាពប្រមូលចំណូល ត្រូវធ្វើការតាមដាន និង ជំរុញជាប្រចាំនូវការអនុវត្តន៍កម្មវិធីប្រមូលចំណូលមិនមែនសារពើពន្ធប្រចាំត្រីមាស និង វិធានការទាន់ពេលវេលាក្នុងករណីចាំបាច់ ជាពិសេស ត្រូវគោរព និង អនុវត្តតាមបទបញ្ជារបស់រាជរដ្ឋាភិបាលស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធលេខ ០៤ បប ចុះថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ ២០០៦ ។

៧- ទន្ទឹមនឹងនេះ ដើម្បីអោយការអនុវត្តន៍កម្មវិធីប្រមូលចំណូលប្រចាំត្រីមាសសំរេចបានប្រកបដោយប្រសិទ្ធភាពខ្ពស់ អង្គភាពនីមួយៗ ត្រូវធ្វើការតាមដាន និង ត្រួតពិនិត្យជាប្រចាំ (ប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ប្រចាំខែ និង ប្រចាំត្រីមាស) លើលទ្ធផលដែលសំរេចបាន ដើម្បីវិធានការទាន់ពេលវេលាក្នុងករណីចាំបាច់ ។ ក្រៅពីការធ្វើរបាយការណ៍អនុវត្តចំណូលប្រចាំសប្តាហ៍ និង ប្រចាំខែ អង្គភាពនីមួយៗត្រូវធ្វើរបាយការណ៍ប្រចាំត្រីមាសស្តីពីការអនុវត្តន៍ចំណូលរបស់ខ្លួនសំរាប់ដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យ និង មានវិធានការតាមរយៈរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយលើកឡើងពីលទ្ធផលដែលសំរេចបាន និង ចំណុចខ្វះខាតដែលបានកត់សំគាល់ ព្រមទាំងលើកឡើងនូវសំណូមពរ និង អនុសាសន៍ដើម្បីកែលំអ និង បង្កើនប្រសិទ្ធភាពប្រមូលចំណូល ។

៨- លើសពីនេះទៅទៀត ដើម្បីធានាការប្រមូលចំណូលតាមគោលនយោបាយនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានដាក់ចេញនូវវិធានការមួយចំនួនដូចខាងក្រោម៖

*ទីមួយ- ការពង្រឹងសមត្ថភាពរួមសំរាប់គ្រប់គ្រង និង ប្រមូលចំណូល:*

- បន្តជំរុញការកសាង និង រៀបចំដាក់អោយអនុវត្តនូវបង្កាន់ដៃជាតិមួយដែលឯកភាព សំរាប់ប្រើប្រាស់ក្នុងការចុះបញ្ជី និង តាមដានការគ្រប់គ្រងលើការប្រមូលចំណូលគ្រប់ប្រភេទ ។
- បន្តជំរុញការរៀបចំយន្តការ និង ណែនាំអោយអនុវត្តប្រកបដោយប្រសិទ្ធភាពនូវបទបញ្ជា និង វិន័យលើការប្រមូលចំណូលថវិការដ្ឋគ្រប់ប្រភេទ ជាពិសេស ចំណូលមិនមែនសារពើពន្ធ ។
- បន្តជំរុញការកសាងបណ្តាជំនាញសនានាដើម្បីពង្រឹងសមត្ថភាពរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុក្នុងការកសាងគោលនយោបាយ និង យន្តការគ្រប់គ្រងកម្មវិធីសមាហរណកម្មពេញលេញនៃការកៀរគរធនធានថវិកា ជាពិសេស ការបង្កើនសមត្ថភាពវិភាគព្យាករណ៍ និង ស្វែងរកប្រភពចំណូលថ្មី ។
- បន្តជំរុញការបង្កើតក្របខ័ណ្ឌសំរាប់កៀរគរ និង បែងចែកចំណូលទៅតាមគ្រប់លំដាប់ថ្នាក់ រដ្ឋបាល និង ផ្តល់ការណែនាំដល់ការកសាងវិធានការ សំដៅបង្កើនធនធានទៅតាមខេត្ត- ក្រុង និង ឃុំ- សង្កាត់ ។
- បន្តជំរុញការកសាងបណ្តាជំនាញសំរាប់រយៈពេលមធ្យម និង វែង ពាក់ព័ន្ធនឹងកម្មវិធីសមាហរណកម្មនៃការកៀរគរធនធានថវិកា សំដៅបំពីនិត្យការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ។
- បន្តជំរុញការកសាងបណ្តាជំនាញក្នុងការធ្វើសមាហរណកម្មការកៀរគរធនធានថវិកា ដើម្បីកំណត់បញ្ចូលទៅក្នុងដំណើរការកសាងថវិកាជាតិ និង ដំណើរការត្រួតពិនិត្យឡើងវិញនៃការអនុវត្តន៍ថវិកាជាតិ ។
- បន្តជំរុញការកំណត់ឱ្យបានច្បាស់លាស់នូវបំណុលពន្ធ និង បំណុលនៃចំណូលមិនមែនសារពើពន្ធ ដើម្បីរៀបចំផែនការប្រមូល និង តឹងទារឱ្យមានប្រសិទ្ធភាព ។
- បន្តជំរុញពង្រឹងការងារសវនកម្ម ទាំងសវនកម្មផ្ទៃក្នុងរបស់ក្រសួង-ស្ថាប័ន ទាំងសវនកម្មផ្ទៃក្រៅ និង ការងារអធិការកិច្ច ទាំងអធិការកិច្ចរបស់រាជរដ្ឋាភិបាល ទាំងអធិការកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុលើការគ្រប់គ្រងថវិកាជាតិជាពិសេសលើការប្រមូលចំណូល ។

*ទីពីរ- ការកៀរគរចំណូលផ្នែកគយ និង រដ្ឋាករ:*

- បន្តជំរុញការកសាង និង ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិខាងផ្នែកគយជាមួយប្រទេសដៃគូរពាណិជ្ជកម្មអន្តរជាតិ ជាពិសេសបណ្តាប្រទេសជាប់ព្រំដែនដើម្បីទប់ស្កាត់អំពើលួចគេចពន្ធ តាមរយៈការផ្តល់ព័ត៌មាន និង ការបញ្ជាក់ទៅវិញទៅមកពាក់ព័ន្ធនឹងការនាំចេញ- នាំចូលមុខទំនិញដែលមានវេទយិតភាពខ្ពស់លើចំណូល ។
- បន្តជំរុញការអនុវត្តន៍វិធានការទប់ស្កាត់ការជ្រាបចូលទីផ្សារ នៃទំនិញដែលនាំចូលតាមរបបអនុគ្រោះនានា ដោយដាក់អោយដំណើរការនូវប្រព័ន្ធជំរះបញ្ជីច្បាស់លាស់ ។

- បន្តពង្រឹងយន្តការត្រួតពិនិត្យទំនិញមុនពេលផ្ទុកបន្ថែមទៀត ដើម្បីកាត់បន្ថយជាអតិបរមានូវទំនិញនាំចូលដែលមិនឆ្លងការត្រួតពិនិត្យទំនិញមុនពេលផ្ទុកអោយបានត្រឹមត្រូវ ។

- បន្តជំរុញការអនុវត្តន៍យន្តការឆ្លងកាត់ជាតិ ដើម្បីយកទំនិញសំខាន់ៗមួយចំនួន មកបំពេញបែបបទនៅជិតតំបន់ប្រើប្រាស់ ជៀសវាងការចំណាយមិនចាំបាច់នានានៅតាមច្រក និង តាមដងផ្លូវ ងាយស្រួលដល់ផ្នែកផ្សេងទៀតជួយឃ្លាំមើល និង សង្កេតការណ៍ ។

- បន្តកែសំរួលនិតិវិធីត្រួតពិនិត្យរបស់គយអោយកាន់តែមានប្រសិទ្ធភាព លើទំនិញនាំចូលនាពេលបំពេញបែបបទបញ្ចេញទំនិញ ពេលដឹកជញ្ជូន ពេលសន្និធិ និង ពេលចរាចរចែកចាយ ។

- បន្តជំរុញការរៀបចំ និង អនុវត្តការធ្វើសវនកម្មក្រោយការយកទំនិញចេញពីគយ ដើម្បីធានាភាពត្រឹមត្រូវនៃប្រតិបត្តិការគយ ។

- បន្តជំរុញការរៀបចំកម្មវិធីបណ្តុះបណ្តាលធនធានមនុស្ស រួមទាំងការជ្រើសរើស និង ហ្វឹកហ្វឺនមន្ត្រី និង ភ្នាក់ងារគយ និង រដ្ឋាករ ។

- បន្តអនុវត្តយុទ្ធសាស្ត្រចាប់បង្ខំ និង គោលការណ៍គ្រប់គ្រងហានិភ័យដើម្បីកាត់បន្ថយការរត់ពន្ធ និង បណ្តាសកម្មភាពខុសច្បាប់ផ្សេងៗនៅតាមព្រំដែន ។

- បន្តជំរុញការពង្រឹងក្របខ័ណ្ឌគតិយុត្តិ ដោយផ្អែកលើច្បាប់គយថ្មីដោយការអនុវត្តន៍យ៉ាងហ្មឹងម៉ាត់ ក្នុងនោះរួមមានទាំងការកសាងគោលនយោបាយគយ និង រដ្ឋាករ និង ការចងក្រងសេចក្តីណែនាំអនុវត្ត នីតិវិធីគយ ។

- បន្តជំរុញការអនុវត្តន៍កម្មវិធីគ្រប់ជ្រុងជ្រោយរបស់គយក្នុងការវិភាគលើចំណូល និង ការផ្តល់តួរលេខចំណូល និង ស្ថិតិពាណិជ្ជកម្មប្រកបដោយបច្ចុប្បន្នភាព និង សុក្រឹតភាព ។

- បន្តជំរុញការអនុវត្តន៍គំរោងបំពាក់បច្ចេកវិទ្យាពត៌មានដល់ទីចាត់ការគយ និង រដ្ឋាករ ហើយរៀបចំវិធានការរយៈពេលខ្លីសំរាប់ការអនុវត្តន៍កម្មវិធីស្វ័យប្រវត្តកម្មគយ រួមទាំងការរៀបចំបង្កើតមូលដ្ឋាន ច្បាប់ និង នីតិវិធីដែលមានការពាក់ព័ន្ធនឹងការបណ្តុះបណ្តាល និង ការរៀបចំគំរោងផង ។

- បន្តជំរុញការកំណត់ និង អនុវត្តវិធានការពង្រឹងស្ថាប័នគយ រួមទាំងការកែលំអរចនាសម្ព័ន្ធនៃការផ្តល់កំរៃ និង ការលើកទឹកចិត្តដល់មន្ត្រីគយ និង ការអភិវឌ្ឍន៍កម្មវិធីអភិបាលកិច្ចល្អផង ។

<u>ទីបី-ការកៀរគរចំណូលពន្ធដារ:</u>

- រៀបចំ និង ដាក់អោយអនុវត្តការវាយតំលៃ សំរាប់គិតអាករពិសេសលើផលិតផលក្នុងស្រុកតាមថ្លៃលក់ចេញពីរោងចក្រកត់ត្រាក្នុងវិក័យប័ត្រ (ex-factory price) ។

- រៀបចំ និង ដាក់អោយអនុវត្តនូវការកែប្រែមូលដ្ឋានសំរាប់ការគិតពន្ធលើដីធ្លីមិនបានប្រើប្រាស់តាមរយៈការធ្វើវិសោធនកម្មមាត្រា ៣០ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ។

- រៀបចំ និង ដាក់អោយអនុវត្តនូវពន្ធលើប្រាក់ចំណេញមូលធន (capital gain) តាមរយៈការធ្វើវិសោធនកម្មមាត្រា ៧ នៃច្បាប់ស្តីពីសារពើពន្ធ ។

- បន្តពង្រឹងការគ្រប់គ្រងប្រមូលអាករពិសេស អាករលើតំលៃបន្ថែម និង យន្តការបង្វិលសង អាករលើតំលៃបន្ថែម ។

- បន្តកែលំអការវិភាគ និង ការព្យាករណ៍លើចំណូលពន្ធដារក្នុងទិសដៅបង្កើតបណ្តាជំរើសគោលនយោបាយថ្មីៗ ដើម្បីបង្កើនចំណូលពន្ធ ។

- បន្តជំរុញការបង្កើនការប្រើប្រាស់ប្រព័ន្ធធនាគារក្នុងកំរិតអតិបរមា ដើម្បីសំរួលដល់ការបង់ពន្ធជាពិសេស ចំពោះអ្នកជាប់ពន្ធប្រភេទធំ និង មធ្យម ។

- បន្តពង្រឹងឱ្យបានគ្រប់ជ្រុងជ្រោយនូវសេវាកម្មពន្ធពិសេសចំពោះអ្នកជាប់ពន្ធប្រភេទធំនិងមធ្យម ។

- បន្តពង្រឹងការគ្រប់គ្រងបំណុលពន្ធ និង អនុវត្តយ៉ាងហ្មឹងម៉ាត់នូវការតឹងទារបំណុលពន្ធដារ ក្នុងនោះរួមមានការអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាពត៌មានសំរាប់កិច្ចប្រតិបត្តិការគ្រប់គ្រង និង ការធ្វើសវនកម្មពន្ធនៅនឹងកន្លែង ព្រមទាំងការជំរះបញ្ជីអ្នកជាប់ពន្ធផងដែរ ។

- បន្តអនុវត្តវិធានការពង្រឹងនាយកដ្ឋានពន្ធដាររួមទាំងការរៀបចំរចនាសម្ព័ន្ធឡើងវិញ ការជ្រើសរើសមន្ត្រីថ្មីបន្ថែម ការកែលំអសេវាបំរើឱ្យអ្នកជាប់ពន្ធ ការអនុវត្តន៍កម្មវិធីបណ្តុះបណ្តាល ការធ្វើសវនកម្មផ្ទៃក្នុង និង ការបំពាក់នូវទុក្ខសំភារៈចាំបាច់ផ្សេងៗ ។ល។

- បង្កើនការផ្ទៀងផ្ទាត់ពត៌មានដើម្បីស្វែងរកផលរបរនៅក្នុងរបបម៉ៅការដែលត្រូវផ្ទេរទៅរបបពិត ។

- ពង្រឹងប្រព័ន្ធត្រួតពិនិត្យ និង ប្រមូលចំណូលពីអាជីវកម្មឆ្នោត និង ល្បែងភ្នាល់ផ្សេងៗ ដោយសិក្សាពីបទពិសោធន៍អន្តរជាតិពាក់ព័ន្ធនឹងជំរើសដែលអាចបង្កើនចំណូលពីអាជីវកម្មឆ្នោត និង បណ្តាល្បែងភ្នាល់នានា ។

- ពង្រឹងក្របខ័ណ្ឌច្បាប់ក្នុងការត្រួតពិនិត្យសកម្មភាពប្រតិបត្តិការកាស៊ីណូ និង ពង្រឹងការប្រមូលចំណូលពីកាស៊ីណូឱ្យបានកើនឡើងសមស្របនឹងចំណូលជាក់ស្តែងនៃអាជីវកម្មក្នុងវិស័យនេះ ក្នុងនោះរួមមានការពង្រឹងសមត្ថភាពរបស់ស្ថាប័ន និង មន្ត្រីដែលទទួលបន្ទុកការងារប្រមូលចំណូលនេះផងដែរ ។

*ទីបួន-ការពង្រឹងការគ្រប់គ្រង និង ការកៀរគរចំណូលមិនមែនសារពើពន្ធ:*

- រៀបចំ និង ដាក់អោយអនុវត្តនូវការផ្តល់វិញ្ញាបនប័ត្រវិជ្ជាជីវៈ និង ការអនុញ្ញាតិលើការប្រកបសេវាកម្មវាយតំលៃ និង ការជួញដូរអចលនវត្ថុ ។

- បន្តចុះសិក្សា និង ស្រាវជ្រាវរាល់បំណុលទាំងអស់ ដើម្បីរៀបចំគោលការណ៍ និង នីតិវិធីតឹងទារ ឬដោះស្រាយតាមផ្លូវច្បាប់ចំពោះបំណុលរ៉ាំរ៉ៃ ។

- បន្តរៀបចំយន្តការ និង ដាក់ចេញនូវវិធានការដើម្បីពង្រឹងក្របខ័ណ្ឌច្បាប់ និង ស្ថាប័ន សំរាប់ការគ្រប់គ្រង និង ប្រមូលចំណូលមិនមែនសារពើពន្ធ ។

- បន្តពង្រឹងការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ។

- បន្តពង្រឹងការគ្រប់គ្រងឯកជនភាវូបនីយកម្មនៃទ្រព្យសម្បត្តិរដ្ឋឱ្យស្របទៅតាមច្បាប់ និង បទបញ្ញត្តិជាធរមាន ។

- បន្តអនុវត្តប្រកបដោយប្រសិទ្ធភាពនូវ វិធានការពង្រឹងការប្រមូលចំណូលពីការជួល ឬ លក់អចលនទ្រព្យ រួមទាំងការពង្រឹងនីតិវិធីនៃការជួល និង ការចុះកិច្ចសន្យាផង ចំណូលពីសហគ្រាសសាធារណៈ តាមរយៈការពង្រឹងក្របខ័ណ្ឌនៃការគ្រប់គ្រងសហគ្រាស ចំណូលពីការលក់ទំនិញ និង ការផ្តល់សេវាសាធារណៈ និង ចំណូលពីការគ្រប់គ្រងធនធានធម្មជាតិគ្រប់ប្រភេទ ។

- បន្តជំរុញការអនុវត្តប្រព័ន្ធដែលផ្តល់អំណាចដល់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការអនុម័តជាចុងក្រោយលើរាល់កិច្ចព្រមព្រៀង និង កិច្ចសន្យាសម្បទានគ្រប់ប្រភេទ ដើម្បីបង្កើនចំណូលពីសម្បទានរបស់រដ្ឋ និង ដើម្បីការពារផលប៉ះពាល់អាក្រក់ដល់ថវិកាជាតិ ។

- បន្តជំរុញការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវវិធានការដាក់វិន័យ ចំពោះក្រសួង-ស្ថាប័ន ឬ មន្ត្រីគ្រប់គ្រងចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទដែលមិនព្រមបង់ចំណូលចូលរតនាគារ ឬ លួចលាក់ចំណូលទុកចាយនៅក្រៅបរិបថនៃថវិកាជាតិ និង ខុសនីតិវិធីច្បាប់ជាធរមាន ។

- បន្តអនុវត្តយ៉ាងហ្មឹងម៉ាត់ និង ជាប់ជាប្រចាំនូវសវនកម្ម និង អធិការកិច្ចលើការអនុវត្តន៍ ភាតព្វកិច្ចបង់ចំណូលពុំមែនសារពើពន្ធរបស់គ្រប់ក្រសួង-ស្ថាប័ន និង សហគ្រាសសាធារណៈដែលមានការពាក់ព័ន្ធ ។

## ខ- ការអនុវត្តន៍ចំណាយថវិកា

៩- ដើម្បីធានាដល់ការអនុវត្តន៍ថវិកាឆ្នាំ ២០០៧ ប្រកបដោយប្រសិទ្ធភាព និង សំរេចបានតាមគោលដៅនៃគោលនយោបាយរបស់រាជរដ្ឋាភិបាល ការគ្រប់គ្រងចំណាយត្រូវបន្តពង្រឹងបន្ថែមទៀត ជាពិសេសត្រូវពង្រឹងការគោរពច្បាប់ហិរញ្ញវត្ថុ និង ការគោរពអោយបានដាច់ខាតនូវវិន័យថវិកាទាំង ១១ ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល ។ ទន្ទឹមនឹងនេះ ត្រូវបន្តពង្រឹងការអនុវត្តន៍អភិបាលកិច្ចល្អក្នុងការអនុវត្តន៍ថវិកា និង ការគ្រប់គ្រងថវិកា ជាពិសេស ការអនុវត្តន៍ឱ្យបានហ្មឹងម៉ាត់នូវរាល់ការកែលំអនៃកំណែទំរង់ហិរញ្ញវត្ថុសាធារណៈ ។

### ខ.១- ការរៀបចំ និង ការអនុវត្តន៍កម្មវិធីចំណូល- ចំណាយ

១០- ដើម្បីអោយការអនុវត្តន៍ថវិកាប្រកបដោយភាពជឿទុកចិត្តបាន និង ប្រព្រឹត្តទៅដោយរលូនជាពិសេស ដើម្បីធានាការឆ្លើយតបទៅនឹងតំរូវការចំណាយជាក់ស្តែង ទាន់ពេលវេលា និង ប្រកបដោយភាពស័ក្តិសិទ្ធិ និង ប្រសិទ្ធភាពខ្ពស់ ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ត្រូវរៀបចំគំរោងកម្មវិធីចំណូល- ចំណាយប្រចាំត្រីមាសសំរាប់រយៈពេលពេញ ១ ឆ្នាំ ដែលមានបែងចែកលំអិតទៅតាមខែ ដោយឈរលើមូលដ្ឋាននៃឥណទានដែលត្រូវបានកំណត់ដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ដើម្បីពិនិត្យ និង វាយតំលៃ ដោយផ្អែកទៅលើអាទិភាពតំរូវការ និង លទ្ធផលចំណូល-ចំណាយជាក់ស្តែង ដើម្បីដាក់ចេញជាកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសសំរាប់ការអនុវត្តន៍ ។ ដោយឡែក មន្ទីរជំនាញខេត្ត-ក្រុងទាំងអស់ ត្រូវផ្ញើទៅមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមួយច្បាប់

ដើម្បីធ្វើការបូកសរុប ហើយផ្ញើមកនាយកដ្ឋានថវិកា សំរាប់ការរៀបចំកម្មវិធីចំណូល- ចំណាយប្រចាំត្រីមាស និង ផ្ញើទៅក្រសួង- ស្ថាប័ន តាមខ្សែបណ្តោយរបស់ខ្លួនមួយច្បាប់ សំរាប់ការគ្រប់គ្រង និង តាមដានការអនុវត្តន៍ ។

១១- ដើម្បីឱ្យនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រៀបចំឱ្យបានល្អ និង ត្រឹមត្រូវនូវការបែងចែកឥណទានថវិកាតាមកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស និង អនុវត្តឱ្យបានសំរេចនូវការអនុវត្តន៍ចំណូល- ចំណាយថវិកាតាមទិសដៅរបស់រាជរដ្ឋាភិបាល ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញ ខេត្ត-ក្រុង ត្រូវអនុវត្តឱ្យបានហ្មឺងម៉ាត់នូវនីតិវិធីដូចខាងក្រោមៈ

- នៅរៀងរាល់ថ្ងៃទី ២០ នៃខែនាចុងត្រីមាសនីមួយៗ នាយកដ្ឋានពន្ធដារ ទីចាត់ការគយ និង រដ្ឋាករ រតនាគារជាតិ នាយកដ្ឋានហិរញ្ញកិច្ច នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ក្រសួង-ស្ថាប័ន និង មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវផ្ញើមកនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នូវរបាយការណ៍អំពីលទ្ធផលនៃការអនុវត្តន៍កម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសកន្លងទៅ និង គំរោងកម្មវិធីចំណូល- ចំណាយប្រចាំត្រីមាសបន្ទាប់ ។
- នាយកដ្ឋានពន្ធដារ ទីចាត់ការគយ និង រដ្ឋាករ រតនាគារ នាយកដ្ឋានហិរញ្ញកិច្ច នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ក្រសួង-ស្ថាប័ន និង មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្ត- ក្រុង ត្រូវផ្ញើរបាយការណ៍អំពីការអនុវត្តន៍ចំណូល- ចំណាយប្រចាំខែ មកនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និង ហិញ្ញវត្ថុអោយបានមុនថ្ងៃទី ១០ នៃខែបន្ទាប់ ។
- នៅរៀងរាល់ថ្ងៃទី ២៥ នៃខែនាចុងត្រីមាសនីមួយៗ នាយកដ្ឋានថវិកាត្រូវកោះប្រជុំពិភាក្សា ជាមួយនាយកដ្ឋានពន្ធដារ ទីចាត់ការគយ និង រដ្ឋាករ រតនាគារជាតិ និង នាយកដ្ឋានពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីរៀបចំកម្មវិធីចំណូល-ចំណាយថវិការដ្ឋសំរាប់ត្រីមាសបន្ទាប់ ។ ផ្អែកលើមូលដ្ឋាននៃកម្មវិធីចំណូល- ចំណាយនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុធ្វើប្រកាសប្រគល់កម្មវិធីចំណូល- ចំណាយសំរាប់ត្រីមាសបន្ទាប់ តាមជំពូកថវិកាក្នុងកំរិតឥណទានអតិបរមាជូនដល់ក្រសួង-ស្ថាប័ននីមួយៗ និងមន្ទីរជំនាញខេត្ត-ក្រុងនីមួយៗ ដោយចម្លងជូននាយកដ្ឋានហិរញ្ញកិច្ច រតនាគារជាតិ និង អភិបាលខេត្ត- ក្រុង ។
- អាណាប័កដើមខ្សែ ឬ អាណាប័កតាមការប្រទានសិទ្ធិ ត្រូវចេញអាណត្តិបើកប្រាក់នៅក្នុងរង្វង់នៃកម្មវិធីចំណាយប្រចាំត្រីមាសរបស់ខ្លួន ហើយនាយកដ្ឋានហិរញ្ញកិច្ច និង រតនាគារជាតិ ត្រូវចុះទិដ្ឋាការលើអាណត្តិបើកប្រាក់ និង ត្រូវបើកជាសាច់ប្រាក់ តែនៅក្នុងកំរិតនៃកម្មវិធីប្រចាំត្រីមាសនេះតែប៉ុណ្ណោះ ។ ក្នុងករណីមានការចាំបាច់សុំបើកផ្តល់បន្ថែម សាមីអង្គភាពត្រូវធ្វើសំណើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ហើយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនឹងធ្វើប្រកាសផ្តល់កម្មវិធីបន្ថែម នៅក្នុងក្របខ័ណ្ឌឥណទានថវិកាដែលមិនទាន់បែងចែកទៅក្នុងកម្មវិធីចំណាយ ។

• រតនាគារជាតិត្រូវបញ្ជូនមកនាយកដ្ឋានថវិកា នូវរបាយការណ៍បេឡាប្រចាំថ្ងៃ របាយការណ៍ចំណូល-ចំណាយថវិកាប្រចាំខែ ព្រមទាំងសាលាកប័ត្របង់ប្រាក់ និង តារាងតុល្យភាពប្រចាំខែ ដើម្បីតាមដានបូកសរុបចំណូល ចំណាយថវិកាប្រចាំខែ ប្រចាំត្រីមាស ព្រមទាំងធ្វើការសន្និដ្ឋាន វាយតំលៃនូវសភាពការណ៍អនុវត្ត ធៀបនឹងខែមុន ត្រីមាសមុន នៃឆ្នាំនេះ និង ប្រៀបធៀបទៅនឹងខែ ត្រីមាសដូចគ្នានៃឆ្នាំមុន ។

• រតនាគារខេត្ត-ក្រុងត្រូវបញ្ជូនមកមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នូវរបាយការណ៍ចំណូល-ចំណាយថវិកាប្រចាំខែ ព្រមទាំងសាលាកប័ត្របង់ប្រាក់ និង តារាងតុល្យភាពប្រចាំខែ ដើម្បីតាមដានបូកសរុបចំណូល-ចំណាយថវិកាប្រចាំខែ ប្រចាំត្រីមាស និង ដើម្បីមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុធ្វើរបាយការណ៍ផ្ញើមកនាយកដ្ឋានថវិកា ។

## ១.២- ការផ្តល់ធានាចំណាយ

- ការផ្តល់ធានាចំណាយ ត្រូវអនុវត្តទៅតាមប្រភេទចំណាយបីដូចខាងក្រោម÷
  - ***ចំណាយបៀវត្ស*** ពុំតំរូវអោយមានធានាចំណាយទេ លើកលែងតែក្រសួងការពារជាតិដែលត្រូវសុំធានាចំណាយ ។
  - ***ចំណាយដែលមិនតំរូវអោយអនុវត្តនិតិវិធីលទ្ធកម្មសាធារណៈ និង ចំណាយដែលមានរបបកំណត់ច្បាស់លាស់*** ពុំតំរូវអោយមានការសុំធានាចំណាយទេ ។
  - ***ចំណាយដែលតំរូវអោយអនុវត្តនិតិវិធីលទ្ធកម្មសាធារណៈ*** តំរូវអោយមានការសុំធានាចំណាយយ៉ាងតិចមួយឆមាសម្តង ទាំងថវិកាតាមកម្មវិធី និង ថវិកាមិនមែនកម្មវិធី ។

• ចំពោះប្រភេទចំណាយដែលមិនតំរូវអោយមានការសុំធានាចំណាយ អាណាប័កត្រូវធ្វើអាណត្តិសុំទូទាត់តែម្តង ដោយមានភ្ជាប់មកជាមួយនូវឯកសារ និង លិខិតយុត្តិការគ្រប់គ្រាន់ស្របទៅតាមនីតិវិធីទូទាត់ ។

• មិនត្រូវអនុញ្ញាតឱ្យមានការធានាចំណាយ និង ការផ្តល់ទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទេ ប្រសិនបើគ្មានការស្នើសុំជាលាយលក្ខអក្សរពីអាណាប័កដើមខ្សែ ឬ អាណាប័កផ្ទេរសិទ្ធិ ទោះបីចំណាយនោះមានកត់ត្រាទុកនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុក៏ដោយ ។

• មិនត្រូវធ្វើការធានាចំណាយ ប្រសិនបើគ្មានឥណទានថវិកានៅសល់ទំនេរ ត្រូវធ្វើការធានាចំណាយទៅតាមឥណទានថវិកាដែលមាន ។

• មិនត្រូវផ្តល់ធានាចំណាយអោយលើសពីឥណទានថវិកាដែលមានលក្ខណៈកំរិតកំណត់ ។

• មិនត្រូវផ្តល់ធានាចំណាយទៅលើការអនុវត្តន៍នូវសកម្មភាព ដែលនាំអោយមានការជ្រើសរើសបុគ្គលិកថ្មី ឬ បុគ្គលិកជាប់កិច្ចសន្យា នៅក្នុងឆ្នាំដែលកំពុងអនុវត្ត ដោយគ្មានការគ្រោងទុកក្នុងថវិកា ឬ គ្មានសេចក្តីសំរេចពីរាជរដ្ឋាភិបាល ។

• មិនត្រូវលើកសំណើចំណាយបន្ថែមប្រសិនបើគ្មានការសន្សំសំចៃពីខ្ទង់ចំណាយដទៃមកជំនួស ។

ខ.៣- ***ការធ្វើលទ្ធកម្មសាធារណៈ***

• គ្រប់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុងទាំងអស់ ត្រូវរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ ដោយផ្អែកលើតម្រូវការជាក់ស្តែង និង គោរពទៅតាមវិធីសាស្ត្រ និង នីតិវិធីលទ្ធកម្មសាធារណៈ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានលទ្ធកម្ម) ដើម្បីពិនិត្យ និង ផ្តល់ការឯកភាព ។

• ការធ្វើលទ្ធកម្មសាធារណៈត្រូវអនុវត្តន៍អោយបានទៀងទាត់ និង ទៅតាមប្រតិទិន ដែលបានកំណត់នៅក្នុងផែនការលទ្ធកម្ម ដែលបានឯកភាពដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ការធ្វើលទ្ធកម្មដែលមិនស្ថិតនៅក្នុងផែនការលទ្ធកម្មនឹងមិនត្រូវបានទទួលស្គាល់ និង មិនធ្វើការទូទាត់ជូនទេ ។

• គ្រប់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុងទាំងអស់ ត្រូវផ្ញើរបាយការណ៍ប្រចាំខែស្តីពីការអនុវត្តន៍លទ្ធកម្ម រួមទាំងទិន្នន័យនៃកិច្ចសន្យា និង ការងារវិសហមផ្សារ មកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុអោយបានទៀងទាត់ ។

• គ្រប់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុងទាំងអស់ ត្រូវគោរពអោយបានហ្មឹងម៉ាត់ ទៅតាមអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ សារាចរណែនាំលេខ ០១២ សហវ ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការរៀបចំផែនការលទ្ធកម្ម និង បទបញ្ញត្តិផ្សេងៗទៀតស្តីពីលទ្ធកម្មសាធារណៈ ។

• តំលៃសរុបនៃកិច្ចសន្យាលទ្ធកម្ម មិនអនុញ្ញាតឱ្យលើសពីឥណទានថវិកាដែលបានផ្តល់ការធានាចំណាយ ឬ ចំនួនទឹកប្រាក់ដែលបានយល់ព្រមផ្តល់មុនបណ្តោះអាសន្នតាមអាណត្តិបើកប្រាក់ឡើយ ។

• មិនអនុញ្ញាតិឱ្យធ្វើការប្រគល់ទទួល ទំនិញ សំណង់ ឬ សេវា ដោយគ្មានកិច្ចសន្យាលទ្ធកម្មឡើយ ព្រោះកិច្ចសន្យាជាមូលដ្ឋានសំខាន់ និង ចាំបាច់បំផុតសំរាប់ធ្វើការទូទាត់ ព្រមទាំងធ្វើការផ្ទៀងផ្ទាត់លក្ខណៈបច្ចេកទេស គុណភាព តំលៃ រយៈពេលផ្គត់ផ្គង់ ឬ សាងសង់ ដែលភាគីទាំងពីរបានព្រមព្រៀងគ្នា ។

• ក្នុងករណីចាំបាច់ដែលតំរូវឱ្យមានការផ្លាស់ប្តូរបញ្ជីចំាន់តំលៃ ឬ លក្ខណៈបច្ចេកទេសនៃ ទំនិញ សំណង់ ឬ សេវា ខុសពីឧបសម្ព័ន្ធនៃកិច្ចសន្យា ត្រូវតែមានការឯកភាពជាលាយលក្ខណ៍អក្សររបស់ភាគីទាំងពីរ និង មានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

• ក្នុងករណីការងារដែលទទួលអនុវត្តដោយអង្គភាពរដ្ឋ ការទូទាត់ត្រូវរក្សាចំនួនទឹកប្រាក់ ១០% នៃតំលៃសរុបរបស់កិច្ចសន្យាទុកជាការធានាគុណភាពជំនួសប្រាក់កក់ រហូតដល់ផុតរយៈពេលធានាគុណភាព ទើបធ្វើការទូទាត់ជូនបង្គ្រប់បញ្ចប់ បន្ទាប់ពីមានកំណត់ហេតុប្រគល់ទទួលបញ្ជាក់ថាបានអនុវត្តត្រឹមត្រូវតាមកិច្ចសន្យា ។

*ខ.៤ - ការទូទាត់ និង ការបើកផ្តល់*

• គ្រប់ក្រសួង- ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុងទាំងអស់ ត្រូវគោរពទៅតាមនិតិវិធី និង បទប្បញ្ញត្តិស្តីពីការត្រួតពិនិត្យហិរញ្ញវត្ថុ និង ការគ្រប់គ្រងចំណាយសាធារណៈ ជាពិសេស ត្រូវរៀបចំសំណើសុំធ្វើការទូទាត់ទៅតាមលំដាប់លំដោយនៃកម្មវិធីចំណាយប្រចាំខែ អោយបានទៀងទាត់ ។

• មិនត្រូវអនុញ្ញាតឱ្យមានការលើកលែងគោលការណ៍នៃបរិបថចំណាយ ការសន្យាចំណាយ ការជំរះបញ្ជី ការធ្វើអាណត្តិបើកប្រាក់ និង ការទូទាត់ លើកលែងតែមានករណីដែលរាជរដ្ឋាភិបាលសំរេចដោយឡែក ។

• ត្រូវធ្វើការទូទាត់ និង បញ្ចេញអាណត្តិបើកប្រាក់ ទៅតាមកម្មវិធីចំណូល- ចំណាយដែលបានកំណត់។

• មិនត្រូវអនុវត្តចំណាយ និង មិនត្រូវទូទាត់ជូនចំពោះចំណាយណាដែលគ្មានលិខិតយុត្តិការគ្រប់គ្រាន់។

• មិនត្រូវធ្វើអាណត្តិបើកប្រាក់ និង មិនត្រូវបញ្ជូនអាណត្តិបើកប្រាក់នោះទៅរតនាគារជាតិបានឡើយប្រសិនបើលិខិតយុត្តិការផ្លូវការមានលក្ខណៈមិនគ្រប់គ្រាន់ ។

• អាចផ្តល់ថវិកាបុរេប្រទានបាន តែក្នុងករណីចាំបាច់ជាបន្ទាន់ ហើយមានឥណទានសល់ទំនេរសំរាប់ចេញអាណត្តិទូទាត់បានក្រោយពីប្រតិបត្តិការចំណាយរួច ។

• អាចផ្តល់មូលនិធិផ្គត់ផ្គង់-ថែទាំផ្លូវថ្នល់បាន លុះត្រាតែមានឥណទានសល់ទំនេរនៅក្នុងគណនីមូលនិធិ ។

• ការចេញអាណត្តិទូទាត់ ត្រូវធ្វើឡើងក្រោយពីការប្រគល់ទទួល ដែលបានកំណត់នៅក្នុងកិច្ចសន្យា ។ ក្នុងករណីតម្លៃកិច្ចសន្យាមានចំនួនទឹកប្រាក់ច្រើនដល់រាប់ពាន់លានរៀលនោះ ការចេញអាណត្តិទូទាត់ត្រូវធ្វើឡើងជាច្រើនជំហានទៅតាមលទ្ធភាពនៃសាច់ប្រាក់ ។

១២- ទន្ទឹមនឹងការអនុវត្តន៍ចំណាយទៅតាមកម្មវិធីចំណូល- ចំណាយ ដំណើរការទូទាត់អាណត្តិបើកប្រាក់ ត្រូវផ្តល់អាទិភាពទៅលើចំណាយចាំបាច់ជាប្រចាំ មានដូចជាប្រាក់បៀវត្ស ប្រាក់អាហារូបករណ៍ ប្រាក់ឧបត្ថម្ភតាមគោលនយោបាយសង្គមកិច្ច ប្រាក់របបអ្នកជំងឺ ការប្រាក់ សងបំណុល ទឹក ភ្លើង ទូរស័ព្ទ វិភាគទានឱ្យអង្គការអន្តរជាតិនានា និង ចំណាយបដិភាគរួមចំណែកជាមួយការវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ និងបន្ទាប់មកត្រូវផ្អែកលើការទូទាត់ដែលមានចែងក្នុងកិច្ចសន្យាលទ្ធកម្មសាធារណៈ ។ ទន្ទឹមនឹងនេះ ត្រូវអនុវត្តវិធានការមួយចំនួន ក្នុងគោលបំណងត្បិតត្បៀត សន្សំសំចៃលើចំណាយសំរាប់កិច្ចដំណើរការរបស់ក្រសួង-ស្ថាប័ន ជាពិសេសចំណាយលើការប្រើប្រាស់សំភារៈការិយាល័យ ប្រេងឥន្ធនៈ ទឹក ភ្លើង ទូរស័ព្ទ និង ចំណាយផ្សេងៗទៀតដែលមិនសូវចាំបាច់ ។

១៣- ដើម្បីឱ្យការអនុវត្តន៍ចំណាយថវិការដ្ឋប្រព្រឹត្តទៅបានទាន់ពេលវេលា និង ជៀសវាងការចំណាយតិចនៅដើមឆ្នាំ ហើយទៅប្រមូលផ្តុំចំណាយច្រើននៅចុងឆ្នាំ និង ម្យ៉ាងវិញទៀត ដើម្បីរក្សាតុល្យភាពថវិកាឱ្យបានរឹងមាំផងនោះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមធ្វើការណែនាំដល់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញនៅតាម

ខេត្ត-ក្រុង ឱ្យដំណើរការអនុវត្តនីតិវិធីចំណាយ ដូចជាការស្នើសុំធានាចំណាយ និង អនុវត្តវិធីសាស្ត្រលទ្ធកម្មសាធារណៈដូចតទៅ÷

• រដ្ឋមន្ត្រីដែលជាអាណាប័កដើមខ្សែ ត្រូវប្រញាប់ប្រញាល់ធ្វើប្រកាសស្តីពីការតែងតាំងអាណាប័កផ្ទេរសិទ្ធិ និង ការផ្ទេរឥណទានថវិកាជូនអភិបាលខេត្ត-ក្រុង ដើម្បីឱ្យមន្ទីរជំនាញរបស់ខ្លួននៅតាមខេត្ត- ក្រុង អាចមានលទ្ធភាពអនុវត្តនូវនីតិវិធីចំណាយបានទាន់ពេលវេលា ។

• ចំណាយថវិការដ្ឋក្នុងការទិញសំភារៈ ជួលសេវា ជួសជុល និង សាងសង់ ត្រូវតែអនុវត្តឱ្យបានហ្មឺងម៉ាត់តាមគោលការណ៍ និង និតិវិធីលទ្ធកម្មសាធារណៈ ។ ចំពោះការអនុវត្តនីតិវិធីដេញថ្លៃសាធារណៈ ត្រូវប្រញាប់ប្រញាល់លើកសំណើសុំគោលការណ៍ធានាចំណាយឆមាស អោយបានទាន់ពេលវេលា មកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្ត-ក្រុង ឱ្យបាននៅដើមឆ្នាំ និង ដើមឆមាស ដើម្បីមានពេលវេលាគ្រប់គ្រាន់សំរាប់អនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ ។ កន្លងមក សាមីក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង មានការយឺតយ៉ាវក្នុងការស្នើសុំធានាចំណាយ ដែលជាហេតុបណ្តាលឱ្យការងារលទ្ធកម្មត្រូវអូសបន្លាយ ហើយការងារទូទាត់ត្រូវពន្យារដល់ចុងឆ្នាំនាំឱ្យចំណាយកើនឡើងគំហុកនៅចុងឆ្នាំ ។ សូមបញ្ជាក់ថា ការស្នើសុំធានាចំណាយសំរាប់អនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ មិនទាក់ទងដល់កម្មវិធីចំណាយទេ គឺទាក់ទងតែឥណទានថវិកាដែលមានកំណត់នៅក្នុងសៀវភៅថវិកាតែប៉ុណ្ណោះ ប៉ុន្តែកម្មវិធីចំណាយត្រូវតែជាក់ស្តែង និង សុក្រឹត ព្រោះវាជាមូលដ្ឋានសំរាប់ការរៀបចំផែនការសាច់ប្រាក់សំរាប់ការបើកផ្តល់ ។

## ខ.៥ - ការអនុវត្តន៍បៀវត្ស ប្រាក់បំណាច់ និង កន្សោមអាទិភាព

១៤- ចំពោះចំនួនក្របខ័ណ្ឌ និង ប្រាក់បៀវត្សរបស់មន្ត្រីរាជការស៊ីវិល មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ និង មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្ត-ក្រុង ត្រូវតែពិនិត្យអនុវត្តតាមព្រះរាជក្រឹត្យលេខ នស/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល អនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០២ ស្តីពីការកែសំរួលប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល និង ប្រាក់ក្នុងវិស័យអប់រំ អនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការបង្កើត និង ដាក់អោយដំណើរការកម្មវិធីកន្សោមអាទិភាព អនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការកែប្រែតំលៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល អនុក្រឹត្យលេខ ១៤០ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការកែប្រែតំលៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល អនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការកែប្រែប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល អនុក្រឹត្យលេខ ៩៨ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការអនុវត្តន៍ប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ អនុក្រឹតលេខ ៣៨ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០៦ ស្តីពីការកែសំរួល ការអនុវត្តន៍ប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ អនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៦ ស្តីពីការបន្ថែមបៀវត្សជូនកងយុទ្ធពលខេមរភូមិន្ទ កងកម្លាំងនគរបាលជាតិ និវត្តជន មន្ត្រីបាត់បង់សមត្ថភាព ពលកម្ម និង យុទ្ធជនពិការ អនុក្រឹត្យលេខ ១៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែ ធ្នូ

ឆ្នាំ ២០០៦ ស្ដីពីការកែប្រែតំលៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល និង តារាងទូទាត់ប្រាក់បៀវត្សតាមប្រព័ន្ធពត៌មានវិទ្យាដែលចេញដោយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។ ក្នុងករណីមានការផ្ទេរមន្ត្រីរាជការពីក្រសួង-ស្ថាប័នមួយ ទៅក្រសួង-ស្ថាប័នមួយទៀតនៅក្នុងឆ្នាំ សាមីខ្លួនត្រូវបន្តទទួលបៀវត្សនៅក្រសួង-ស្ថាប័នដើមរហូតដល់ដំណាច់ឆ្នាំ ហើយត្រូវធ្វើការផ្ទេរ និង គ្រោងបៀវត្សនៅក្រសួង-ស្ថាប័នដែលបានផ្ទេរចូលអោយទាន់ពេលនៅឆ្នាំបន្ទាប់ ។ ចំពោះការអនុវត្តន៍កន្សោមអាទិភាព ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្តក្រុងទាំងអស់ ក្រោយពីបានទទួលសេចក្ដីសំរេចពីក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ត្រូវធ្វើសំណើសុំថវិកាមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជាបន្ទាន់ ដើម្បីអោយការអនុវត្តន៍កន្សោមអាទិភាពនេះប្រព្រឹត្តទៅដោយរលូន និង មានប្រសិទ្ធភាព ។ ចំពោះកម្មវិធីកន្សោមអាទិភាពដែលត្រូវអនុវត្តបន្ត ត្រូវធ្វើសំណើសុំថវិកាមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ យ៉ាងយូរត្រឹមថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៧ ដោយមានភ្ជាប់មកជាមួយនូវរបាយការណ៍នៃការអនុវត្តន៍កម្មវិធីកន្សោមអាទិភាពកន្លងមក និង សេចក្ដីសំរេចរបស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។

### ខ.៦ - ***ការផ្ទេរចលនាឥណទានថវិកា***

១៥- ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ត្រូវប្រើប្រាស់ឥណទានថវិការបស់ខ្លួន ទៅតាមប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុដូចមានលំអិតនៅក្នុងសៀវភៅថវិកា ។ នៅដើមត្រីមាសទី២ ក្រោយពីការអនុវត្តន៍ត្រីមាសទី១ ចប់សព្វគ្រប់មក ក្នុងករណីដែលមានខ្ទង់ចំណាយថវិកាណាមួយមានឥណទានមិនគ្រប់គ្រាន់តែចាំបាច់ត្រូវចំណាយ ត្រូវធ្វើសំណើសុំនិយ័តភាពមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ពិនិត្យ និង សំរេចជាមុនសិន ទើបលើកសំណើសុំខ្ទង់ចំណាយនោះបាន ។ បើក្រសួងស្ថាប័ន មានសំណូមពរ ផ្ដល់ឥណទានបន្ថែម ដូចជាចំណាយដំណើរការរដ្ឋបាល សំភារៈ ការជួសជុលតូច ការសាងសង់ និង ទុព្វសំភារៈ ។ល។ ទៅឱ្យមន្ទីរជំនាញរបស់ខ្លួននៅខេត្ត-ក្រុង នោះគឺត្រូវធ្វើឡើងដោយប្រកាសផ្ទេរឥណទានរបស់ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីឱ្យអភិបាលខេត្ត-ក្រុង (អាណាប័កតាមការប្រទានសិទ្ធិ) ដែលជាខ្សែទទឹង និង មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អាចតាមដានការប្រើប្រាស់ឥណទានថវិកាបន្ថែមទាំងនោះបាន ។

## III. **ការតាមដានការអនុវត្តន៍ថវិកា និង ការធ្វើរបាយការណ៍**

១៦- ដើម្បីបង្កើនគណនេយ្យភាព និង ការទទួលខុសត្រូវចំពោះលទ្ធផលនៃចំណាយសាធារណៈ ជាពិសេស ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តន៍ថវិកា គ្រប់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុងទាំងអស់ ត្រូវធ្វើការតាមដានការអនុវត្តន៍ថវិការបស់ខ្លួនជាប្រចាំ និង ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និង ប្រចាំឆ្នាំ ហើយផ្ញើរមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) អោយបានទៀងទាត់ ទៅតាមគំរូដែលបានផ្ញើជូន និង នៅតាមកាលបរិច្ឆេទដូចខាងក្រោម៖

- របាយការណ៍ប្រចាំខែមុន ត្រូវផ្ញើរមកយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១០ នៃខែបន្ទាប់

- របាយការណ៍ប្រចាំត្រីមាសមុន ត្រូវផ្ញើមកយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ នៃខែ នៅដើមត្រីមាសបន្ទាប់
- របាយការណ៍ឆមាសទី១ ត្រូវផ្ញើមកយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ ខែ មិថុនា
- របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្ញើមកយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៨

## IV. **វិធានការរក្សាតុល្យភាព និង ប្រសិទ្ធភាពថវិកា**

**១៧-** នៅពេលដែលពិនិត្យឃើញថា ស្ថានភាពនៃការអនុវត្តន៍ថវិកានឹងមិនអាចសំរេចបានទៅតាមការគ្រោងទុក ដើម្បីរក្សាតុល្យភាព និង ប្រសិទ្ធភាពថវិកា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានវិធានការដូចខាងក្រោម៖

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនឹងធ្វើការត្រួតពិនិត្យលើការអនុវត្តន៍ថវិកាពាក់កណ្តាលឆ្នាំ ដើម្បីជាមូលដ្ឋានក្នុងការធ្វើថវិកាកែតំរូវក្នុងករណីចាំបាច់ ។
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មិនអនុញ្ញាតិអោយមានការបោះផ្សាយអាណត្តិតំកល់ទុកសំរាប់ចំណាយនៅឆ្នាំបន្ទាប់ឡើយ ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា ក្រសួង-ស្ថាប័ន និង ខេត្ត-ក្រុង ទាំងអស់នឹងរួមសហការក្នុងការអនុវត្តថវិកាឆ្នាំ ២០០៧ របស់យើងអោយសំរេចបានជោគជ័យតាមការគ្រោងទុក ដើម្បីបំរើអោយការអនុវត្តន៍ **យុទ្ធសាស្ត្រចតុកោណ** របស់សម្តេចនាយករដ្ឋមន្ត្រី ដើម្បី ***កំណើន ការងារ សមធម៌*** និង ***ប្រសិទ្ធភាព*** និង ឆ្លើយតបទៅនឹង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ដើម្បី ***កាត់បន្ថយភាពក្រីក្ររបស់ប្រជាជន*** ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**ចំលងជូន**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័តមាន"
- គ្រប់ក្រសួង- ស្ថាប័ន
- គ្រប់ខេត្ត- ក្រុង
  "ដើម្បីអនុវត្ត"
- រាជកិច្ច
  "ដើម្បីផ្សព្វផ្សាយ"
- ឯកសារ- កាលប្បវត្តិ